62/15

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ២៧៣៨ "ល"

ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ ៦២៧៤

ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩

-សំណុំរឿងស៊ើបសួរលេខ ៧៥៣

ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០

-សំណុំរឿងជំនុំជម្រះលេខ ៥៧២

ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ វេលាព្រឹក នៅសាលសវនាការទី៣ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦២៧៤ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] វចនា ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មន្ត្រីនគរបាលជាតិ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] "ស្លាប់" ម្ដាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់ ជានីតិជន ទោសពីមុន គ្មាន។

-ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៦៧៦៥ "ជ១" ង.ព.ង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

២-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ ប្រធានការិយាល័យ ទីកន្លែងកំណើតនៅ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ ... "ស្លាប់" ម្ដាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូន ០៣នាក់ ជានីតិជន ទោសពីមុន គ្មាន។

-ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៦៧៦៤ "ជ១" ង.ព.ង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០។

-មានលោក [redacted] និមល លោក [redacted] ចាន់ណែត លោក [redacted] ឡឹកសីហ៍ និងលោក [redacted] ហេង ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

៣-ជនជាប់ចោទឈ្មោះ [redacted] សុខុម ភេទប្រុស អាយុ ៥៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មន្ត្រីរាជការ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ [redacted]



Scanned with CamScanner

[redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ជានីតិជន ទោសពីមុន គ្មាន។

-ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៦៧៦៣ "ជ១" ដ.ព.ដ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០។

-មានលោក [redacted] និមល លោក [redacted] ចាន់ណែត លោក [redacted] ឡឹកសីហ៍ និងលោក [redacted] ហេង ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

៤-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ជានីតិជន ទោសពីមុន គ្មាន។

-ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៦៧៦២ "ជ១" ដ.ព.ដ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០។

-មានលោក [redacted] ឡឹកសីហ៍ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ជាប់ចោទពីបទ ឆបោក ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃខ្វាលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណី៖

១-ឈ្មោះ [redacted] ស្រ៊ីអ៊ុយ ភេទប្រុស កើតឆ្នាំ១៩៦០ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ [redacted] រាជធានីភ្នំពេញ។

២-ឈ្មោះ [redacted] គុង ភេទប្រុស កើតឆ្នាំ១៩៥៦ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] រាជធានីភ្នំពេញ។

៣-ឈ្មោះ [redacted] វ៉ាន់ឃូ ភេទប្រុស កើតឆ្នាំ១៩៥៤ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះ [redacted] រាជធានីភ្នំពេញ។

៤-ឈ្មោះ [redacted] អេង ភេទស្រី កើតឆ្នាំ១៩៥៧ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] ខេត្តត្បូងឃ្មុំ។

-មានលោក [redacted] គីណាល់ លោកស្រី [redacted] ណារី លោក [redacted] មនោរម្យ ជាមេធាវីតំណាងឱ្យដើមបណ្តឹង។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សារន់ ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ បានចុះកិច្ចព្រមព្រៀងលក់ទិញដីជាមួយដើមបណ្តឹងឈ្មោះ [redacted] ស្រ៊ីអ៊ុយ ឈ្មោះ ណម [redacted] ឈ្មោះ [redacted] វ៉ាន់ឃូ និងឈ្មោះ [redacted] អេង លើផ្ទៃដីសរុបចំនួន ៤១០,៤៦ (បួនរយដប់ក្បៀសសែសិបប្រាំមួយ) ហិកតា ដែលមានទីតាំងទី១ មានទំហំសរុប ២៣១,៤១ (ពីររយសាមសិបមួយក្បៀសសែសិបមួយ) ហិកតា មានទីតាំងស្ថិតនៅភូមិចំការចេក១ ឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង និងទីតាំងទី២ មានទំហំ ១៧៩,០៥ (មួយរយចិតប្រាំបួនក្បៀសសូន្យប្រាំ) ហិកតា មានទីតាំងស្ថិតនៅភូមិព្រៃខ្វាលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង តាមតម្លៃដែលបានឯកភាពដូចនៅក្នុងកិច្ចព្រមព្រៀង។ ចាប់តាំងពីថ្ងៃចុះកិច្ចព្រមព្រៀងលក់ទិញដីលើកទី១ រហូតមកដល់ថ្ងៃទី១៧ ខែតុលា



Scanned with CamScanner

ឆ្នាំ២០១៨ ភាគីអ្នកលក់ទាំងបួននាក់ដែលមានឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សុខុម ឈ្មោះ [redacted] សារ៉ន់ និងឈ្មោះ [redacted] សុវណ្ណ បានទទួលប្រាក់ជាបន្តបន្ទាប់ពីភាគីអ្នកទិញ ដែលមានឈ្មោះ [redacted] ស្រីអ៊ិយ ឈ្មោះ [redacted] ឡុង ឈ្មោះ [redacted] វ៉ាន់យូ និងឈ្មោះ [redacted] អេង សរុបចំនួន ២.០៣១.៣៨២ (ពីរលានសូន្យសែនបីម៉ឺនមួយពាន់បីរយប៉ែតសិបពីរ) ដុល្លារអាមេរិក រួចហើយ តែភាគីអ្នកលក់ពុំមានដីប្រគល់ឱ្យភាគីអ្នកទិញឡើយ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៦៦៣ អ.យ.ណ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣១៨ អ.យ.ឆ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៧៤៩ "ជ១" ដ.ជ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់លោកចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-លោក [redacted] គីណាល់ ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា៖ ខ្លួនស្នើសុំឱ្យតុលាការបន្តនីតិវិធី។ មូលហេតុដែលកូនក្តីខ្លួនប្តឹងជនជាប់ចោទទាំងបួននាក់នោះ ដើមឡើយកូនក្តីខ្លួនបានដើររកទិញដី ហើយជនជាប់ចោទទាំងបួននាក់បានមកទាក់ទងកូនក្តីខ្លួនដើម្បីលក់ដី ហើយពួកគាត់បានអះអាងថាជាម្ចាស់ដីពិតប្រាកដក្នុងការលក់ទិញដីមកឱ្យកូនក្តីខ្លួន។ មុនពេលឈានដល់កិច្ចព្រមព្រៀងនៃការលក់ទិញកូនក្តីខ្លួនបានសួរបញ្ជាក់ដែរថា ដីនោះមានពាក់ព័ន្ធជារបស់អ្នកណាដែរ ឬអត់ ឬក៏ពួកគាត់គ្រាន់តែជាអ្នកភ្នាក់ងារប្រមូលទិញ តែជនជាប់ចោទបានឆ្លើយថា ពួកគាត់គឺជាអ្នកម្ចាស់ដី មិនមានពាក់ព័ន្ធជាមួយនឹងអ្នកផ្សេងទេ ចឹងហើយកូនក្តីខ្លួនក៏សម្រេចចិត្តទិញដី ក្នុងនោះដែរកូនក្តីខ្លួនមានគ្នាបួននាក់ ហើយជនជាប់ចោទមានគ្នាបួននាក់អះអាងថាជាម្ចាស់ដី ចឹងនៅពេលធ្វើការចុះកិច្ចព្រមព្រៀងគឺមានពីរដំណាក់កាលដោយមានការបញ្ជាក់ពីការលក់ទិញទំហំដី និងទីតាំងដីពិតប្រាកដ ពេលបញ្ជាក់ពីទំហំដី ហើយមុនឈានដល់ការចុះកិច្ចព្រមព្រៀងដំណាក់កាលទី១ ជនជាប់ចោទបានបញ្ជាក់ទំហំដី ដែលមានទីតាំងដូចមាននៅក្នុងកិច្ចព្រមព្រៀង កូនក្តីខ្លួនក៏បានសម្រេចចិត្តធ្វើកិច្ចសន្យាលក់ទិញ និងបានចុះកិច្ចសន្យាកក់ប្រាក់ ហើយការកក់ប្រាក់នោះកូនក្តីខ្លួនក៏បានទូទាត់ជាដំណាក់កាលដែរ ក៏ប៉ុន្តែនៅពេលដែលកូនក្តីខ្លួនកក់ប្រាក់មួយចំនួន ជនជាប់ចោទក៏បានទៅយកឯកសារដីដែលបញ្ជាក់ថាខ្លួនជាម្ចាស់កម្មសិទ្ធិលើដីនោះ ហើយទាំងកូនក្តីខ្លួនមិនដឹងថាដីនោះជាដីរបស់អ្នកដទៃទេ តែដោយសារជនជាប់ចោទបញ្ជាក់ថាដីនោះជារបស់គាត់ កូនក្តីខ្លួនបានកក់ប្រាក់ជាបន្តបន្ទាប់តែម្តង ហើយប្រាក់ដែលប្រគល់ឱ្យជនជាប់ចោទមានចំនួនប្រហែល ២លានដុល្លារជាង។ នៅពេលដែលធ្វើនីតិវិធីនៃការប្រគល់ប្លង់ក្រោយពេលកក់ប្រាក់ហើយ ស្រាប់តែជនជាប់ចោទមិនមានដី ពេលនោះកូនក្តីខ្លួនក៏បានចុះទៅស្រាវជ្រាវដល់ទីតាំងដី បញ្ជាក់ពីមូលហេតុថា តើដីនោះជាដីរបស់ជនជាប់ចោទដែលអះអាងមែនឬអត់ ក៏បានសួរទៅខាងមេភូមិដែលជាសាក្សីក៏បានបញ្ជាក់ថា ដីដែលប្រជាពលរដ្ឋបានលក់ដីនោះឈ្មោះ [redacted] រចនា គឺបានលុយទៅកក់ថ្លៃដីបានចំនួនតែ ២០$ ដែលមានប្រជាពលរដ្ឋរហូតដល់ចំនួន ១២៤គ្រួសារ ចឹងហើយក្នុងន័យនេះគឺជនជាប់ចោទមិនមានដីខ្លួនឯងពិតប្រាកដទេ ហើយក្រោយពេលកូនក្តីខ្លួនបានស្រាវជ្រាវថាមិនមានដី ហើយជាដីរបស់ប្រជាពលរដ្ឋដែលបានអះអាង ប្រជាពលរដ្ឋក៏បានអះអាងដូចគ្នានឹងមេភូមិរំចេកទី១ ដែលបានអះអាងថាដីនោះមិនមែនជាដីរបស់ជនជាប់ចោទទេ ជារបស់ប្រជាពលរដ្ឋ ដែលជនជាប់ចោទបានកក់ប្រាក់ឱ្យប្រជាពលរដ្ឋបានម្នាក់ប្រហែល២០$ទេ ក្រោយមកលុយនោះអ្នកខ្លះបានទទួល និងអ្នកខ្លះទៀតមិនបានទទួលទេ ហើយប្រជាពលរដ្ឋក៏បានយកដីវិញអស់ ក្នុងនោះក៏បានបែករឿង ទើបកូនក្តីខ្លួនបានទាក់ទងមកពិភាក្សារឿងមិនមានដី តែមិនមានអ្នកណាមកដដែក

ពិភាក្សាពីបញ្ហាដីនោះទេ និងបានគេចខ្លួនរហូតមកដល់សព្វថ្ងៃនេះ ទើបកូនក្តីខ្លួនដាក់ពាក្យបណ្តឹងអ្នកទាំងបួននោះពីបទឆបោក។ ខ្លួនសូមបញ្ជាក់បន្ថែមថា នៅពេលដែលកូនក្តីខ្លួនដាក់ពាក្យបណ្តឹង អយ្យការបានធ្វើការចោទប្រកាន់រហូតមកដល់មានការបញ្ជូនមកជំនុំជម្រះ ស្រាប់តែជនជាប់ចោទឈ្មោះ [redacted]សារ៉ន់ បានធ្វើរបាយការណ៍មួយបញ្ជូនមកតុលាការអំពីនីតិវិធីនៃការបិទផ្សាយនៃការធ្វើប្លង់ ឃើញថាក្នុងឋានៈគាត់ជាជនជាប់ចោទហេតុអ្វីគាត់មិនធ្វើកិច្ចការនេះ រហូតមកដល់ពេលធ្វើការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះហើយទើបគាត់ធ្វើឯកសារបញ្ជាក់ថា មានការបិទផ្សាយលើដីដែលលក់ឱ្យកូនក្តីខ្លួន ហើយក្នុងនោះឯកសាររបស់សាលាខេត្តក៏បានបញ្ជាក់ដែរថា នីតិវិធីនោះគឺមិនត្រឹមត្រូវទេ ដោយសារដីនោះជាដីរបស់ប្រជាពលរដ្ឋ ចឹងសួរថាតើក្នុងនាមគាត់ជាជនជាប់ចោទ និងបានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបបានបង្គាប់ឱ្យគាត់ដាក់ប្រាក់តម្កល់ម្នាក់ៗផ្សេងៗគ្នា ហើយគាត់សន្យាថានឹងយកប្រាក់មកតម្កល់ក្រោយពេលចេញទៅវិញ តែបាត់រហូត ស្រាប់តែមានការបិទផ្សាយធ្វើប្លង់។ គាត់គួរតែត្រូវបានផ្អាកពីការងារក្នុងពេលដែលគាត់កំពុងត្រូវបានចោទប្រកាន់ពីតុលាការ បែបនេះមិនគួរទៅធ្វើឯកសារផ្សេងៗទេ។ បើទោះបីជាឯកសារនៃការបិទផ្សាយមានភាពត្រឹមត្រូវ ក៏អាជ្ញាធរខេត្តបានបញ្ជាក់ថា ពុំមានលក្ខណៈត្រឹមត្រូវទេ ហើយប្រជាពលរដ្ឋបាននាំគ្នាតវ៉ាយកដីវិញអស់ហើយ ហើយយកដីនោះបិទផ្សាយមកលក់ឱ្យកូនក្តីខ្លួនគឺមិនត្រឹមត្រូវ។ ចំណុចនេះហើយដែលបញ្ជាក់ឱ្យឃើញថាជនជាប់ចោទទាំងបួននាក់មានចេតនាទុច្ចរិតតាំងពីដំបូងមកម្ល៉េះ ដោយគាត់គ្មានដីពិតប្រាកដ គាត់បានក្លែងថាខ្លួនជាម្ចាស់ដី ធ្វើយ៉ាងណាឱ្យកូនក្តីខ្លួនមានការជឿជាក់តាមការអះអាងរបស់ជនជាប់ចោទ ធ្វើឱ្យកូនក្តីខ្លួនខាតប្រាក់ជាហូរហែររហូតអស់ប្រហែល២លានដុល្លារជាង ចឹងចំណុចនេះឃើញថា ផ្អែកតាមសាក្សី និងភស្តុតាងដែលមាននៅក្នុងសំណុំរឿងបានបញ្ជាក់ហើយថា គ្មានដីទេ ដីនោះជាដីរបស់ប្រជាពលរដ្ឋ ចឹងភស្តុតាងបញ្ជាក់មកនេះឃើញថា ជនជាប់ចោទបានឆបោកយកប្រាក់ពីកូនក្តីខ្លួនពិតប្រាកដមែន។ ហើយក្នុងនោះដែរជនជាប់ចោទក៏បានលើកឡើងថា ដីបានកាត់កងជាមួយកូនក្តីខ្លួនដែលមានទំហំស្មើនឹងទឹកប្រាក់២លានដុល្លារ ខ្លួនសូមបញ្ជាក់ថា កូនក្តីខ្លួនឈ្មោះ [redacted] វ៉ាន់យូរ បានធ្វើលិខិតបំភ្លឺចូលមកចៅក្រមស៊ើបសួរ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ អំពីពាក្យស្នើសុំឱ្យបំពេញកិច្ចរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានលើកឡើងថា ដីដែលបានប្រគល់មកឱ្យកូនក្តីខ្លួនទាំងបួននាក់ស្មើនឹងទឹកប្រាក់ដែលពួកគាត់បានទទួល ជាក់ពិតដីនេះគឺជាដីដោយឡែកមិនជាប់ពាក់ព័ន្ធនឹងការលក់ទិញដី ៤០០ហិកតាជាងនោះទេ ចឹងអត់មានពាក់ព័ន្ធលិខិតកាត់កងជាមួយគ្នាដូចការលើកឡើងរបស់មេធាវីជនជាប់ចោទស្នើសុំបំពេញកិច្ចនោះទេ។ ចំណុចនេះជនជាប់ចោទទាំងបួននាក់ព្យាយាមដោះបន្ទុកអំពីកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តមកលើកូនក្តីរបស់ខ្លួន ការលើកឡើងរបស់ជនជាប់ចោទទាំងបួននាក់រហូតមកដល់ពេលជំនុំជម្រះនេះ គឺពុំទាន់មានឯកសារណាមួយបញ្ជាក់ថា ពួកគាត់មានដីត្រឹមត្រូវនោះទេ ចឹងចំណុចទាំងអស់នេះខ្លួនស្នើសុំឱ្យតុលាការមេត្តាពិនិត្យពិចារណា ផ្តន្ទាទោសជនជាប់ចោទទាំងបួននាក់តាមផ្លូវច្បាប់ និងសុំទាមទារសំណងដូចក្នុងពាក្យបណ្តឹងរបស់កូនក្តីខ្លួន។

-លោកស្រី [redacted]ណារី ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា៖ ដោយសារតែភស្តុតាងនៅក្នុងសំណុំរឿងនេះកូនក្តីខ្លួនបានភ្ជាប់ជូនអស់ហើយ ដូចមានកិច្ចសន្យាពីរច្បាប់ ហើយកិច្ចសន្យាទាំងពីរនោះគឺមានការប្រគល់ប្រាក់ជាបន្តបន្ទាប់ ហើយអ្នកដែលទទួលគឺជនជាប់ចោទតែម្តងជាអ្នកទទួល ដោយសន្យាថាខ្លួនមានដី ហើយដីនោះជាដីរបស់ខ្លួន។ ពាក់ព័ន្ធនឹងចម្លើយសាក្សីផ្សេងៗទៀត និងភស្តុតាងផ្សេងៗនៅក្នុងសំណុំរឿងនេះមានន័យថា ជនជាប់ចោទពុំមានដីទាល់តែសោះ ហើយគាត់បានក្លែងថាដីរបស់ខ្លួន និងបានលក់មកឱ្យកូនក្តីខ្លួន រហូតមកដល់ពេលនេះគាត់នៅតែព្យាយាមដោះបន្ទុក ដោយទាក់ទងនឹងកូនក្តីខ្លួនថា ធ្វើការព្យាយាមដោះស្រាយជាមួយកូនក្តីខ្លួន តែកូនក្តីខ្លួនមកដល់ពេលនេះគឺមិនទាន់បានដីពីជនជាប់ចោទនៅឡើយទេ ហើយភាគីជនជាប់ចោទគឺពុំមានដីនៅក្នុងរឿងនេះទាល់តែសោះ ចឹងពាក់

ព័ន្ធនឹងចេតនាទុច្ចរិតរបស់គាត់គឺមានតាំងពីដំបូង មុនពេលបង្កើតកិច្ចសន្យាលក់ដីមកឱ្យកូនក្តីរបស់ខ្លួន ឃើញថាជនជាប់ចោទមានការសហការគ្នាយ៉ាងល្អ ដោយសារពួកគាត់សុទ្ធតែមានតួនាទីជាមន្ត្រីរាជការ ដូចជាឈ្មោះ [redacted] សុខុម គឺជាមន្ត្រីនៅខាងសុរិយោដី និងឈ្មោះ [redacted] សារន់ គឺជាអធិការស្រុកតែម្តង ចឹងពាក់ព័ន្ធនឹងវិធីសាស្ត្រក្នុងការឆបោកកូនក្តីខ្លួនដើម្បីឱ្យមានការជឿជាក់គឺដោយសារគាត់មានតួនាទីខ្លះដែរ។ ពាក់ព័ន្ធជាមួយនឹងការស្នើសុំចុងក្រោយ ខ្លួនស្នើសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងបួននាក់ឱ្យបានតឹងរឹងបំផុត ដើម្បីកុំឱ្យពួកគាត់ប្រើប្រាស់តួនាទីក៏ដូចជាអំណាចរបស់គាត់ធ្វើបាបគេទៀត ឃើញថាករណីនេះគឺជារឿងព្រហ្មទណ្ឌសុទ្ធសាធ ពាក់ព័ន្ធនឹងបទចោទខាងលើខ្លួនស្នើសុំឱ្យតុលាការផ្តល់សំណងឱ្យកូនក្តីខ្លួនចំនួន ២លានដុល្លារជាង ដែលបានបាត់បង់ និងសំណងជំងឺចិត្តចំនួន ៥០០,០០០$ ផង។

-តុលាការឱ្យក្រឡាបញ្ជីអានពាក្យសុំបិត្តឹរបស់ឈ្មោះ [redacted] វ៉ាន់យូ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០។

-តុលាការឱ្យក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយឈ្មោះ [redacted] ឡុង នៅដំណាក់កាលចៅក្រមស៊ើបសួរ។ ៩

-តុលាការឱ្យក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយឈ្មោះ [redacted] វឿន នៅដំណាក់កាលចៅក្រមស៊ើបសួរ។ ៩

-តុលាការឱ្យក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយឈ្មោះ [redacted] សុខុម នៅដំណាក់កាលចៅក្រមស៊ើបសួរ។ ៩

-តុលាការឱ្យក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយជនជាប់ចោទឈ្មោះ ម៉ាន់ រចនា នៅដំណាក់កាលចៅក្រមស៊ើបសួរ។

-តុលាការឱ្យក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយជនជាប់ចោទឈ្មោះ [redacted] សារន់ នៅដំណាក់កាលចៅក្រមស៊ើបសួរ។

-តុលាការឱ្យក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយជនជាប់ចោទឈ្មោះ [redacted] សុខុម នៅដំណាក់កាលចៅក្រមស៊ើបសួរ។

-តុលាការឱ្យក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ នៅដំណាក់កាលចៅក្រមស៊ើបសួរ។

-មេធាវីតំណាងឱ្យដើមបណ្តឹងបានបញ្ជាក់ថា៖ ខ្លួនសូមបញ្ជាក់ជូនតុលាការថា ការពិតគឺជនត្រូវចោទពុំមានដីទេ ត្បិតតែក្នុងចម្លើយរបស់គាត់បានឆ្លើយថាមានដីប្រគល់ឱ្យ តែជាក់ស្តែងកូនក្តីខ្លួនទិញដីចង់បានដី ហើយក្នុងចំនួនណាមួយជាក់លាក់ក៏មិនមានដែរ ចំនួនដី១០៨ហិកតានោះក៏មិនបានទទួលដែរ ស្របពេលដែលប្រជាពលរដ្ឋបានបញ្ជាក់ថា មិនបានប្រគល់លុយឱ្យពួកគាត់ផង ចឹងពួកគាត់យកដីត្រឡប់ទៅវិញធ្វើស្រែចំការ ហើយឯកសារថាមាន គឺនៅក្រោយពេលដែលតុលាការធ្វើការចោទប្រកាន់បញ្ជូនទៅជម្រះហើយក្នុងឆ្នាំ២០២០ ក្រោយពេលមានបណ្តឹងមកតុលាការហើយ។ ហើយកន្លងមកខាងជនជាប់ចោទក៏ធ្លាប់បានទាក់ទងមកធ្វើការដោះដូរទៅយកដីនៅខេត្តកំពតវិញ មានន័យថាគាត់ពិតជាមិនមានដីដែលលក់ឱ្យកូនក្តីខ្លួននោះទេ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-លោក [redacted] គីណាល់ ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានធ្វើការបញ្ជាក់ ក៏ដូចជាការស្តាប់នូវអំណានចម្លើយរបស់សាក្សី និងជនជាប់ចោទរួចមកឃើញថា ក្នុងរឿងនេះជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើឆបោកមកលើកូនក្តីខ្លួនដូចអ្វីដែលខ្លួនបានបញ្ជាក់ខាងលើរួចហើយ ហេតុនេះខ្លួនស្នើសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទពីបទ ឆបោក និងសុំឱ្យចេញដីកាចាប់ខ្លួនតាមមាត្រា ៣៥៣ ដើម្បីឱ្យជនជាប់ចោទមកទទួលទណ្ឌកម្មតាមផ្លូវច្បាប់។



Scanned with CamScanner

62/10

-លោកស្រី [redacted] ណារី ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី និងចម្លើយរបស់ជនជាប់ចោទរួចមកឃើញថា ខ្លួនបានបញ្ជាក់ហើយថា ជនជាប់ចោទក្នុងរឿងនេះគឺមិនមានដីពិតប្រាកដមែន ហើយបែរជាមកឆបោកកូនក្តីខ្លួនថាមានដីសម្រាប់លក់ឱ្យកូនក្តីខ្លួន និងអះអាងថាខ្លួនជាម្ចាស់កម្មសិទ្ធិលើដីទៅទៀត ទើបធ្វើឱ្យកូនក្តីខ្លួនជឿទុកចិត្ត សម្រេចចិត្តទិញ និងបានកក់ប្រាក់ តែពេលបានទទួលលុយកក់ហើយបែរជាគ្មានដីប្រគល់ឱ្យកូនក្តីខ្លួនទៅវិញ ហេតុនេះជាសំណូមស្នើសុំឱ្យតុលាការសម្រេចផ្តន្ទាទោសពួកគាត់តាមច្បាប់ ដោយសារពួកគាត់គឺជាមន្ត្រីរាជការទៀតផង ជាពិសេសស្នើសុំឱ្យតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន និងសុំទាមទារជំងឺចិត្តដូចក្នុងសេចក្តីសន្និដ្ឋានដែលបានដាក់ជូនតុលាការរួចហើយ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី ក៏ដូចជាចម្លើយរបស់ដើមបណ្តឹង និងចម្លើយរបស់ជនជាប់ចោទរួចមកឃើញថា ក្នុងអង្គហេតុនេះជនជាប់ចោទទាំងបួននាក់គឺបានទទួលលក់ទិញដីឱ្យដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីធ្វើកិច្ចសន្យាលក់ទិញនោះមក ជនជាប់ចោទមិនមានដីប្រគល់ឱ្យដើមបណ្តឹងដូចការអះអាងនោះ ទើបធ្វើឱ្យមានការបំពានក៏ដូចជាការភូតកុហកដើមបណ្តឹងរដ្ឋប្បវេណី ដែលបញ្ជាក់បានថាជនជាប់ចោទទាំងបួននាក់នោះ មានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើស ដូច្នេះឃើញថាអំពើរបស់ជនជាប់ចោទគឺជាចេតនាឆបោក ហេតុនេះតំណាងអយ្យការស្នើសុំតម្កល់ការចោទប្រកាន់លើជនជាប់ចោទទាំងបួននាក់តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ទុកនៅដដែល និងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសតាមកំណត់ច្បាប់។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-ជនជាប់ចោទឈ្មោះ [redacted] វចនា ឈ្មោះ [redacted] សារ៉ន់ ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះពីបទ ឆបោក ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃទួលថ្មី ឃុំក្រចៅ ស្រុកកំចាយមារ ខេត្តព្រៃវែង បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២-តាមពាក្យបណ្តឹង ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ បានប្តឹងថា៖ កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ពួកខ្លួនបានចុះកិច្ចព្រមព្រៀងលក់ទិញដីជាមួយភាគីអ្នកលក់ដីមានឈ្មោះ [redacted] វចនា ឈ្មោះ [redacted] សារ៉ន់ ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ លើផ្ទៃដីទំហំសរុប ៤១០,៤៦ ហិកតា ដែលដីទីតាំងទី១ មានទំហំសរុប ២៣១,៤១ ហិកតា ស្ថិតនៅភូមិចំការចេក១ ឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង និងដីទីតាំងទី២ មានទំហំ ១៧៩,០៥ ហិកតា មានទីតាំងស្ថិតនៅភូមិព្រៃទួលថ្មី ឃុំក្រចៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។ គិតចាប់ពីថ្ងៃចុះកិច្ចព្រមព្រៀងលក់ទិញដីលើកទី១ រហូតមកដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ ភាគីអ្នកលក់ដីទាំងបួននាក់ខាងលើគឺមានឈ្មោះ [redacted] វចនា



Scanned with CamScanner

ឈ្មោះ [redacted] សារន់ ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ បានទទួលប្រាក់ថ្លៃលក់ទិញដីពីខ្លួនជាបន្តបន្ទាប់អស់ចំនួន ២.០៣១.៣៨២$ រួចហើយ។ ភាគីអ្នកលក់ដីទាំងបួននាក់ខាងលើបានធានាអះអាងថា ដីដែលជាកម្មវត្ថុនៃការលក់ទិញក្នុងកិច្ចព្រមព្រៀងជាដីកម្មសិទ្ធិស្របច្បាប់របស់ខ្លួនពិតប្រាកដមែន ដោយពុំមានជាប់ពាក់ព័ន្ធជាមួយដីអ្នកផ្សេង ឬក៏យកដីរបស់អ្នកផ្សេងមកលក់ដោយពុំទាន់បានទូទាត់ប្រាក់ឱ្យម្ចាស់ដីឡើយ។ ប៉ុន្តែផ្ទុយទៅវិញ ក្រោយពួកគេបានទទួលប្រាក់ថ្លៃលក់ទិញដីពីខ្លួនរួចហើយ បែរជាពួកគេពុំមានដីប្រគល់ឱ្យខ្លួនឡើយ។ ម្យ៉ាងវិញទៀត ទោះបីខ្លួនបានស្នើសុំជួប ឬទូរស័ព្ទទំនាក់ទំនងដើម្បីសួរនាំក៏ដោយ ក៏ជនទាំងនេះព្យាយាមគេចវេះ មិនមកជួបពិភាក្សាជាមួយខ្លួនដោះស្រាយបញ្ហាឡើយ។

៣-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ក្លូង បានឆ្លើយថា ខ្លួនជាមេឃុំក្របៅ សុំរក្សាចម្លើយនៅអយ្យការដដែល។ ខ្លួនសូមបញ្ជាក់ថា កន្លងមកខ្លួនធ្លាប់ឃើញឈ្មោះ [redacted] រចនា ទៅប្រមូលទិញដីពីប្រជាពលរដ្ឋនៅភូមិព្រៃទួលថ្មីបានមួយចំនួន តែពុំដឹងទំហំប៉ុន្មានទេ ហើយក៏ពុំដឹងតម្លៃដែលគេលក់ទិញដែរ ព្រោះពេលគេយកឯកសារសុំហត្ថលេខាពុំបានដាក់តម្លៃទេ។ ចំពោះផ្ទៃដីបង្កបង្កើនផល និងផ្ទៃដីចំការសរុបមានចំនួន ១១១ហិកតា ប៉ុណ្ណោះ។

៤-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ជឿន បានឆ្លើយថា ខ្លួនឈ្មោះ [redacted] ជឿន ជាមេភូមិចំការចេក១ សុំឆ្លើយបំភ្លឺជូនតុលាការថា ខ្លួនសូមរក្សាចម្លើយដែលបានឆ្លើយនៅដំណាក់កាលអយ្យការទុកជាបានការដដែល។ កន្លងមកខ្លួនធ្លាប់ឃើញឈ្មោះ [redacted] រចនា ទៅប្រមូលទិញដីពីប្រជាពលរដ្ឋនៅភូមិចំការចេក១ ឃុំក្រញូង មាន ១២៤គ្រួសារ ដោយទិញក្នុងហិកតា ១ម៉ឺនដុល្លារអាមេរិក។ ក្នុងចំណោមគ្រួសារខាងលើខ្លះបានលុយគ្រប់ ខ្លះទៀតមិនទាន់បាន ខ្លះបានតែលុយកក់ចំនួន ២០$ ជាដើម។ ក្រោយមកប្រជាពលរដ្ឋបានមករកខ្លួនឱ្យសួរនាំឈ្មោះ [redacted] រចនា តែឈ្មោះ [redacted] រចនា បានប្រាប់ថា គាត់គ្មានប្រាក់ឱ្យទេ គាត់សុំប្រគល់ដីឱ្យម្ចាស់ដើមវិញ។ ក្រោយមកខាងក្រុមហ៊ុនបានមកសួរខ្លួនថា លុយបានប្រគល់ជាង ២លានដុល្លារ ហើយម៉េចមិនប្រគល់ឱ្យប្រជាពលរដ្ឋ? ពេលនោះខ្លួនបាននាំក្រុមហ៊ុនទៅសួរប្រជាពលរដ្ឋដែលលក់ដីពួកគាត់ថាពុំទាន់ទទួលបានប្រាក់ពីឈ្មោះ [redacted] រចនា ទេ។ ចំពោះផ្ទៃដីបង្កបង្កើនផលនៅក្នុងភូមិចំការចេក១ មានទំហំប្រហែល ១៧០ហិកតា ចំណែកដីចំការមានទំហំប្រហែល ១០០ហិកតា។ ហើយតាមដែលខ្លួនបានដឹងឮថា ក្រុមហ៊ុននឹងចុះទៅទិញដីនៅភូមិខ្លួនចំនួន ១៧០ហិកតា ដែលមានឈ្មោះ [redacted] រចនា ជាអ្នកដើរទិញ ហើយទិញតែដីចំការទេ តែទិញមិនទាន់គ្រប់ទេ។ ក្នុងការលក់ទិញនេះ ខាងមេភូមិ និងឃុំពុំបានដឹង និងសហការជាមួយឈ្មោះ [redacted] រចនា ទេ គឺគេចុះរាស់វែងខ្លួនឯងជាមួយនឹងម្ចាស់ដីផ្ទាល់តែម្តង។

៥-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សុខុម បានឆ្លើយថា ក្នុងនាមខ្លួនជាមេឃុំក្រញូង សូមឆ្លើយជូនតុលាការជ្រាបថា ខ្លួនសុំរក្សាចម្លើយដែលបានឆ្លើយនៅអយ្យការទុកជាបានការដដែល គឺខ្លួនពិតជាបានឃើញឈ្មោះ [redacted] រចនា ចុះទៅប្រមូលទិញដីពីប្រជាពលរដ្ឋនៅភូមិចំការចេក ឃុំក្រញូង និងមានប្រជាពលរដ្ឋទៅសុំហត្ថលេខាពីខ្លួនលើលិខិតលក់ទិញនោះដែរ។ ខ្លួនពុំបានដឹងពីទំហំដីសរុបពិតប្រាកដដែលប្រជាពលរដ្ឋលក់ឱ្យទៅក្រុមហ៊ុននោះទេ ព្រោះប្រជាពលរដ្ឋមកម្តង ២ឬ៣នាក់ ដើម្បីសុំហត្ថលេខា។ តាមខ្លួនសួរប្រជាពលរដ្ឋ គេប្រាប់ថាលក់ដីក្នុង ១ហិកតា តម្លៃ ១ម៉ឺនដុល្លារអាមេរិក។

៦-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] រចនា បានឆ្លើយថា ខ្លួនសុំរក្សាចម្លើយដែលបានឆ្លើយនៅដំណាក់កាលអយ្យការទុកជាបានការដដែល ពុំមានអ្វីកែប្រែទេ។ ចំពោះលុយជាង ២លានដុល្លារនេះគឺក្រុមខ្លួនបានទទួលសែកដែលចេញមកឱ្យខ្លួនទៅបើកលុយឱ្យទៅម្ចាស់ដី និងខ្លះទៀតក្រុមហ៊ុនចេញឱ្យទៅម្ចាស់ដីផ្ទាល់។ ដីដែលត្រូវទិញក្នុងកិច្ចសន្យាគឺ ២លានជាង ទិញបានជាង ៤០០ហិកតា ក្នុងតម្លៃ ៤.៥០០ ដុល្លារក្នុងមួយហិកតា។ ប៉ុន្តែពេលទៅទិញផ្ទាល់ជាក់ស្តែងដីខ្លះឡើងថ្លៃដល់ ១០.០០០$ ខ្លះ ១៥.០០០$ រហូតដល់ ១៨.០០០$ ទៀត ទើបធ្វើឱ្យការទិញដីពុំគ្រប់តាមកំណត់

0012 05138 Nou Chanthy

ក្នុងកិច្ចសន្យា ហើយពួកខ្លួនទិញបានតែ ៣៨ហិកតា ក្នុងឃុំក្រពៅ ៦៨ហិកតា ក្នុងឃុំក្រញូង និងនៅតាមផ្លូវ៨A ក្នុងភូមិព្រៃកទួលថ្មី ឃុំក្រពៅ ជិត២ហិកតាទៀត សរុបប្រហែល ១០៨ហិកតា។ ក្នុងលុយជាង ២លានដុល្លារ ពួកខ្លួនទិញដីអស់នៅសល់ប្រហែល ៧០ម៉ឺនដុល្លារ គឺចំណាយទៅលើការរត់ការកាត់ឈ្មោះ និងថ្លៃចាយវាយផ្សេងៗអស់ហើយ។ ចំពោះដី ៦៨ហិកតា នៅឃុំក្រញូង ពួកខ្លួន និងក្រុមហ៊ុនពិតជាបានចុះវាស់វែង និងផ្ទេរសិទ្ធិជូនក្រុមហ៊ុនរួច ដោយរត់ដល់សុរិយោដី ហើយ តែចេញប្លង់បាន ឬអត់ខ្លួនពុំដឹងទេ ៣៨ហិកតាទៀតផ្ទេរបានត្រឹមស្រុក និង២ហិកតា ចុងក្រោយផ្ទេរត្រឹមឃុំ។

៧-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានឆ្លើយថា ខ្លួនសូមរក្សាចម្លើយដែលបានឆ្លើយនៅដំណាក់កាលអយ្យការទុកនៅដដែល ពុំមានអ្វីកែប្រែទេ។ ខ្លួនបានឯកភាពជាមួយចម្លើយរបស់ឈ្មោះ [redacted] រចនា ដែលជាក្រុមការងារជាមួយគ្នា។ ក្រុមខ្លួនមានឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សុខុម ឈ្មោះ [redacted] សារន់ និងខ្លួន ពិតជាបានចុះកិច្ចព្រមព្រៀងទិញដីនៅភូមិចំការចេក១ ឃុំក្រញូង និងភូមិទួលថ្មី ឃុំក្រពៅ ទំហំ ៣១៨ហិកតា ដោយក្នុងមួយហិកតា តម្លៃ ៤.៥០០$ ប្រាកដមែន។ ចំពោះលុយដែលទទួលបានជាសែកមានចំនួនជាង ២លានដុល្លារមែន ក្រុមហ៊ុនបានបើកឱ្យពួកខ្លួន និងបើកឱ្យម្ចាស់ដីផ្ទាល់ខ្លះ។ ដោយសារដីឡើងថ្លៃបន្តបន្ទាប់ ទើបធ្វើឱ្យពួកខ្លួនទិញដីពុំបានគ្រប់ចំនួន ដោយបានតែ ៣៨ហិកតា នៅឃុំក្រពៅ និងឃុំក្រញូង ៦៨ហិកតា ប៉ុណ្ណោះ។ ពួកខ្លួនបានរៀបចំធ្វើលិខិតផ្ទេរសិទ្ធិដីឱ្យទៅក្រុមហ៊ុនដូចដែលឈ្មោះ [redacted] រចនា បានឆ្លើយ។

៨-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ ពិន សារន់ បានឆ្លើយថា ខ្លួនសុំរក្សាចម្លើយដែលបានឆ្លើយនៅអយ្យការទុកជាបានការដដែលពុំមានកែប្រែទេ។ ខ្លួនបានចូលរួមក្រុមក្នុងការទិញដីឱ្យក្រុមហ៊ុនជាមួយឈ្មោះ [redacted] រចនាដែរ ដោយគ្រាន់តែឈរឈ្មោះ ហើយខ្លួនពុំបានចុះទៅវាស់វែង ឬទៅធ្វើការទិញដីពីម្ចាស់ផ្ទាល់ទេ ខ្លួនគ្រាន់តែធ្លាប់បានទៅទទួលសែកពីក្រុមហ៊ុនប៉ុណ្ណោះ។ ចំនួនលុយសរុបដែលក្រុមហ៊ុនទម្លាក់ឱ្យជាសែកសរុបប្រហែល ២លានដុល្លារ ដោយតម្រូវឱ្យទិញដីជាង ៣០០ហិកតា ពេលនោះគឺ ១ហិកតា ៤.៥០០$ តែការទិញជាក់ស្តែងបានតែប្រហែល ១០៧ហិកតាប៉ុណ្ណោះក៏អស់លុយ។ ខ្លួនពុំដឹងថាឈ្មោះ [redacted] រចនា យកលុយទៅធ្វើអ្វីខ្លះទើបអស់នោះទេ ព្រោះគាត់ជាអ្នកគ្រប់គ្រងសែកដែលក្រុមហ៊ុនបើកឱ្យ។ មូលហេតុដែលទិញដីមិនគ្រប់តាមកិច្ចព្រមព្រៀង ដោយសារតែដីឡើងថ្លៃជាបន្តបន្ទាប់ ហើយម្ចាស់លុយក៏បានឯកភាពទិញតាមលុយនោះដែរ។

៩-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សុខុម បានឆ្លើយថា ខ្លួនសុំរក្សាចម្លើយដែលបានឆ្លើយនៅអយ្យការទុកជាបានការដដែលពុំមានអ្វីកែប្រែទេ។ ដំបូងឈ្មោះ [redacted] រចនា បានបបួលខ្លួនឱ្យចូលរួមរៀបចំទិញដីដែលស្ថិតនៅឃុំក្រពៅ ឃុំក្រញូង ឱ្យទៅក្រុមហ៊ុនមួយក្នុងតម្លៃ ៤.៥០០$ ក្នុងមួយហិកតា ដោយឱ្យខ្លួនគ្រាន់តែឈរឈ្មោះប៉ុណ្ណោះ រាល់ការទិញ រៀបចំឯកសារ គឺឈ្មោះនេះជាអ្នករៀបចំ។ ឯខ្លួន គេហៅទៅចូលរួមពេលទៅទទួលសែកពីម្ចាស់លុយដោយឱ្យខ្លួនផ្តិតមេដៃអីងឮដែរ។ ចំពោះការទិញដីបានប៉ុន្មានហិកតា និងការទទួលលុយជាសែកពីក្រុមហ៊ុនប៉ុន្មាន ខ្លួនពុំដឹងទេ។ កន្លកមកឈ្មោះ [redacted] រចនា ធ្លាប់សន្យាជាមួយខ្លួនថា គាត់ជាអ្នកទទួលខុសត្រូវទាំងស្រុងតែម្នាក់ឯង ដោយពុំឱ្យខ្លួនពាក់ព័ន្ធឡើយ។ ដូចមានក្នុងលិខិតបញ្ជាក់របស់ឈ្មោះ ម៉ាន់ រចនា ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ ស្រាប់។

១០-តាមការបញ្ជាក់របស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថា កូនក្តីខ្លួនបានដើររកទិញដី ហើយជនជាប់ចោទទាំងបួននាក់បានមកទាក់ទងកូនក្តីខ្លួនដើម្បីលក់ដី ហើយពួកគាត់ធានាអះអាងថាជាម្ចាស់ដីពិតប្រាកដក្នុងការលក់ទិញដីមកឱ្យកូនក្តីខ្លួន កូនក្តីខ្លួនក៏បានសួរបញ្ជាក់ដែរថាដីនោះមានពាក់ព័ន្ធជារបស់អ្នកណាដែរឬអត់ ឬក៏ពួកគាត់គ្រាន់តែជាអ្នកភ្នាក់ងារប្រមូលទិញ តែជនជាប់ចោទបានឆ្លើយថា ពួកគាត់គឺជាអ្នកម្ចាស់ដី មិនមានពាក់ព័ន្ធជាមួយនឹងអ្នកផ្សេងទេ។ ទើបកូនក្តីខ្លួនក៏សម្រេចចិត្តទិញដីនោះ ជនជាប់ចោទបានអះអាងថាជាម្ចាស់ដី ចឹងនៅពេលធ្វើការចុះកិច្ច



Scanned with CamScanner

ព្រមព្រៀងគឺមានពីរដំណាក់កាល ដោយមានការបញ្ជាក់ពីការលក់ទិញ ទំហំដី និងទីតាំងដីពិតប្រាកដ ពេលបញ្ជាក់ពីទំហំដី ហើយមុនឈានដល់ការចុះកិច្ចព្រមព្រៀងដំណាក់កាលទី១ ជនជាប់ចោទបានបញ្ជាក់ទំហំដី កូនក្តីខ្លួនក៏បានសម្រេចចិត្តធ្វើកិច្ចសន្យាលក់ទិញ និងបានចុះកិច្ចសន្យាកក់ប្រាក់ ហើយប្រាក់កក់នោះកូនក្តីខ្លួនក៏បានទូទាត់ជាដំណាក់កាលដែរ ក៏ប៉ុន្តែនៅពេលដែលកូនក្តីខ្លួនកក់ប្រាក់មួយចំនួន ជនជាប់ចោទក៏បានទៅយកឯកសារដីដែលបញ្ជាក់ថាខ្លួនជាម្ចាស់កម្មសិទ្ធិលើដីនោះ ហើយទាំងកូនក្តីខ្លួនមិនដឹងថា ដីនោះជាដីរបស់អ្នកដទៃទេ តែដោយសារជនជាប់ចោទបញ្ជាក់ថាដីនោះជារបស់គាត់ កូនក្តីខ្លួនក៏បានកក់ប្រាក់ជាបន្តបន្ទាប់តែម្តង ហើយប្រាក់ដែលប្រគល់ឱ្យជនជាប់ចោទចំនួនប្រហែល២លានដុល្លារជាង។ នៅពេលដែលធ្វើនីតិវិធីនៃការប្រគល់ប្លង់ ក្រោយពេលកក់ប្រាក់ហើយ ស្រាប់តែជនជាប់ចោទមិនមានដី ពេលនោះកូនក្តីខ្លួនបានចុះទៅស្រាវជ្រាវដល់ទីតាំងដី បានសួរទៅខាងមេភូមិដែលជាសាក្សីក៏បានដឹងថា ដីដែលប្រជាពលរដ្ឋបានលក់នោះបញ្ជាក់ថាឈ្មោះ [redacted] រចនា គឺបានយកលុយទៅកក់ថ្លៃដីបានចំនួនតែ ២០$ ដែលមានប្រជាពលរដ្ឋរហូតដល់ចំនួន ១២៤ គ្រួសារ ចឹងហើយគឺជនជាប់ចោទមិនមានដីខ្លួនឯងពិតប្រាកដទេ ហើយក្រោយពេលកូនក្តីខ្លួនបានស្រាវជ្រាវថាមិនមានដី ហើយជាដីរបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋក៏បានអះអាងដូចគ្នានឹងមេភូមិចំការចេកទី១ ក៏បានអះអាងថា ដីនោះមិនមែនជាដីរបស់ជនជាប់ចោទទេ ជារបស់ប្រជាពលរដ្ឋដែលជនជាប់ចោទបានកក់ប្រាក់ឱ្យប្រជាពលរដ្ឋបានម្នាក់ប្រហែល ២០$ទេ ក្រោយមកលុយនោះអ្នកខ្លះបានទទួល និងអ្នកខ្លះទៀតមិនបានទទួលទេ ហើយប្រជាពលរដ្ឋក៏បានយកដីវិញអស់ក្នុងនោះក៏បានបែករឿង ទើបកូនក្តីខ្លួនបានទាក់ទងមកពិភាក្សារឿងមិនមានដី តែមិនមានអ្នកណាមកជជែកពិភាក្សាពីបញ្ហាដីនោះទេ និងបានគេចខ្លួនរហូតមកដល់សព្វថ្ងៃនេះ ទើបកូនក្តីខ្លួនដាក់ពាក្យបណ្តឹងអ្នកទាំងបួននោះពីបទ ឆបោក។ ចំណុចនេះហើយដែលបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទទាំងបួននាក់មានចេតនាទុច្ចរិតតាំងពីដំបូងមកម្ល៉េះ ដោយគាត់គ្មានដីពិតប្រាកដ គាត់បានក្លែងថាខ្លួនជាម្ចាស់ដី ធ្វើយ៉ាងណាឱ្យកូនក្តីខ្លួនមានការជឿជាក់តាមការអះអាងរបស់ជនជាប់ចោទ ធ្វើឱ្យកូនក្តីខ្លួនកក់ប្រាក់ជាហូរហែររហូតអស់ប្រហែល២លានដុល្លារជាង ចឹងចំណុចឃើញថា ផ្អែកតាមសាក្សី និងភស្តុតាងដែលមាននៅក្នុងសំណុំរឿងបានបញ្ជាក់ហើយថា គ្មានដីទេ ដីនោះជាដីរបស់ប្រជាពលរដ្ឋ ហេតុនេះភស្តុតាងបញ្ជាក់មកនេះឃើញថា ជនជាប់ចោទបានឆបោកយកប្រាក់ពីកូនក្តីខ្លួនពិតប្រាកដមែន។ ជនជាប់ចោទពុំដីទាល់តែសោះ ហើយគាត់បានក្លែងថាដីរបស់ខ្លួន និងបានលក់មកឱ្យកូនក្តីខ្លួន រហូតមកដល់ពេលនេះគាត់នៅតែព្យាយាមដោះបន្ទុកទាក់ទងនឹងខ្លួនដោយថាបានធ្វើការព្យាយាមដោះស្រាយជាមួយកូនក្តីខ្លួន តែកូនក្តីខ្លួនមកដល់ពេលនេះ គឺមិនទាន់បានដីពីជនជាប់ចោទនៅឡើយទេ ហើយភាគីជនជាប់ចោទគឺពុំមានដីនៅក្នុងរឿងនេះទាល់តែសោះ ចឹងពាក់ព័ន្ធនឹងចេតនាទុច្ចរិតរបស់គាត់គឺមានតាំងពីដំបូង មុនពេលបង្កើតកិច្ចសន្យាលក់ដីមកឱ្យកូនក្តីរបស់ខ្លួន។ ខ្លួនស្នើសុំឱ្យតុលាការផ្តល់សំណងឱ្យកូនក្តីខ្លួនចំនួន ២លានដុល្លារជាងដែលបានបាត់បង់ និងសំណងជំងឺចិត្តចំនួន ៥00,000$ ផង។

១១-តាមកិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ រវាងឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សារន់ ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ ជាមួយនឹងឈ្មោះ [redacted] តុង និងកិច្ចព្រមព្រៀងបន្ថែម ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សារន់ ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ ជាមួយនឹងឈ្មោះ [redacted] តុង ឈ្មោះ [redacted] ស្រីអ៊ុយ ឈ្មោះ [redacted] វ៉ាន់យូរ និងឈ្មោះ [redacted] អេង អាចបញ្ជាក់បានថា ជនជាប់ចោទទាំងបួននាក់ ពិតជាបានចុះកិច្ចព្រមព្រៀងជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការលក់ទិញដីចំនួន ២៣១,៤១ (ពីររយសាមសិបមួយក្បៀសសែសិបមួយ) ហិកតា មានទីតាំងនៅភូមិចំការចេក១ ឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង និងមានចំនួន១៧៩,០៥ (មួយរយចិតសិបប្រាំបួនក្បៀសសូន្យប្រាំ) ហិកតា មានទីតាំងស្ថិតនៅភូមិព្រៃទួលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ឱ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងបួននាក់ប្រាកដមែន ហើយនៅក្នុងកិច្ចព្រមព្រៀងនោះ ជនជាប់ចោទថែមទាំងបានអះអាងទៀតថា ដីដែល



Scanned with CamScanner

62/6

ជាកម្មវត្ថុនៃការលក់ទិញ គឺពិតជាដីកម្មសិទ្ធិរបស់ខ្លួនពិតប្រាកដមែន ដោយពុំមានជាប់ពាក់ព័ន្ធជាមួយអ្នកផ្សេង ឬក៏យកដីរបស់អ្នកផ្សេងមកលក់ដោយពុំទាន់បានទូទាត់ប្រាក់ឱ្យម្ចាស់ដីឡើយ។

១២-តាមភស្តុតាងជាឯកសារមូលប្បទានប័ត្រ និងលិខិតប្រគល់ និងទទួលប្រាក់ចំនួន២០លើក ដែលដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទបានដាក់ជូនតុលាការឃើញថា ជនជាប់ចោទទាំងបួននាក់ពិតជាបានទទួលប្រាក់ពីដើមបណ្តឹងរដ្ឋប្បវេណីជាបន្តបន្ទាប់ ដោយបានទទួលជាសាច់ប្រាក់ និងបានទទួលជាមូលប្បទានប័ត្រសរុបមានចំនួន ២.០៣១.៣៨២ (ពីរលានសាមសិបមួយពាន់បីរយប៉ែតសិបពីរ) ដុល្លារអាមេរិក ដែលជាប្រាក់សម្រាប់ទូទាត់ថ្លៃទិញដីពីប្រជាពលរដ្ឋប្រាកដមែន។

១៣-ផ្អែកតាមពាក្យសុំបញ្ចូលភស្តុតាងឱ្យតុលាការពិនិត្យដោយគូភាគី និងចម្លើយបញ្ជាក់របស់សាក្សីដែលជាមេភូមិ និងមេឃុំនៃទីតាំងដីជាកម្មវត្ថុនៃការលក់ទិញឃើញថា ទីតាំងដីជាក់ស្តែងនៅក្នុងភូមិចំការចេកទី១ ឃុំក្រញូង និងភូមិព្រៃទួលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង មិនមានដីចំការជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ឬជាកម្មសិទ្ធិរបស់ជនជាប់ចោទទាំងបួននាក់សម្រាប់ធ្វើជាកម្មវត្ថុនៃការលក់ទិញរហូតដល់ទំហំ ៤១០,៤៦ (បួនរយដប់ក្បៀសសែសិបប្រាំមួយ) ហិកតាដូចមានក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងកិច្ចព្រមព្រៀងបន្ថែម ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ រវាងរវាងជនជាប់ចោទឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សារន់ ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] តុង ឈ្មោះ [redacted] ស្រីអ៊ិយ ឈ្មោះ [redacted] វ៉ាន់យូរ និងឈ្មោះ [redacted] អេង ទេ។ ជាងនេះទៅទៀត ការអះអាងថាជនជាប់ចោទទាំងបួននាក់គឺជាម្ចាស់ដីទំហំរហូតដល់ជាង ៤០០ ហិកតា នៅក្នុងភូមិ និងឃុំខាងលើ ក៏មិនមានលក្ខណៈសមហេតុផលអាចឱ្យជឿបាននោះដែរ។

១៤-ក្នុងសកម្មភាពនៃការប្រមូលទិញដីពីប្រជាពលរដ្ឋម្ចាស់ដីពិតប្រាកដនៅក្នុងភូមិចំការចេកទី១ ឃុំក្រញូង និងភូមិព្រៃទួលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ដោយជនជាប់ចោទទាំងបួននាក់ គឺធ្វើឡើយក្រោមរូបភាពរៀបចំជាតារាងឈ្មោះរបស់ម្ចាស់ដី ទំហំដីកាន់កាប់ជាក់ស្តែង និងតម្លៃលក់ពិតប្រាកដឱ្យទៅអ្នកទិញជាដើមបណ្តឹងរដ្ឋប្បវេណីទាំងបួននាក់ រួចបង្កើតជាកិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងកិច្ចព្រមព្រៀងបន្ថែម ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ដើម្បីទទួលបាននូវការកក់ប្រាក់ និងការបង់ប្រាក់ថ្លៃលក់ទិញដីជាដំណាក់កាលជាបន្តបន្ទាប់ស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងទាំងពីរដែលបានធ្វើជាមួយគ្នា។

១៥-ផ្អែកតាមលិខិតប្រគល់ទទួលប្រាក់ជាច្រើនលើក រវាងជនជាប់ចោទទាំងបួននាក់ជាមួយនឹងដើមបណ្តឹងទាំងបួននាក់ដែលត្រូវបានបង់ជាដំណាក់កាលនោះឃើញថា មានទឹកប្រាក់មួយចំនួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងបួននាក់ត្រូវបានប្រគល់ដោយផ្ទាល់ និងត្រូវបានប្រគល់ជាមូលប្បទានប័ត្រឱ្យទៅជនជាប់ចោទទាំងបួននាក់ដោយផ្ទាល់ ហើយក៏មានការប្រគល់ប្រាក់ជាមូលប្បទានប័ត្រជាច្រើនសន្លឹកពីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] តុង តាមរយៈជនជាប់ចោទទាំងបួននាក់ ប្រគល់ឱ្យទៅប្រជាពលរដ្ឋជាម្ចាស់ដីពិតប្រាកដ ដោយបានដាក់ឈ្មោះរបស់ម្ចាស់ដីពិតប្រាកដ រួមជាមួយនឹងទំហំទឹកប្រាក់ដែលត្រូវបង់ជាក់ស្តែងតែម្តងដូចមានក្នុងតារាងរៀបចំដោយជនជាប់ចោទទាំងបួននាក់។

១៦-ផ្អែកតាមពាក្យសុំបញ្ចូលភស្តុតាងឱ្យតុលាការពិនិត្យដោយគូភាគី និងចម្លើយបញ្ជាក់របស់សាក្សីដែលជាមេភូមិ និងមេឃុំនៃទីតាំងដីទំនាស់ ឯកសារពាក់ព័ន្ធនានា ជាពិសេសលិខិតប្រគល់ទទួលប្រាក់២០លើក និងមូលប្បទានប័ត្រដែលដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] តុង បានបើកឱ្យទៅជនជាប់ចោទទាំងបួននាក់ ក៏ដូចជាប្រជាពលរដ្ឋជាម្ចាស់ដីពិតប្រាកដជាច្រើនសន្លឹក ដែលមានលក្ខណៈស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងខ្លឹមសារនៃកិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងកិច្ចព្រមព្រៀងបន្ថែម ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ដែលអាចឱ្យតុលាការជឿជាក់បានថា សកម្មភាពនៃ



Scanned with CamScanner

ការលក់ទិញដីរវាងជនជាប់ចោទទាំងបួននាក់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីទាំងបួននាក់គឺ ពុំអាចមានជាដីពិតប្រាកដសម្រាប់ជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញនោះទេ ផ្ទុយទៅវិញវាគឺជាកិច្ចសន្យាអាណត្តិ ដែលមានគោលបំណងឱ្យជនជាប់ចោទទាំងបួននាក់ជួយរៀបចំ និងប្រមូលទិញដីពីប្រជាពលរដ្ឋជាម្ចាស់ដីពិតប្រាកដនៅក្នុងភូមិចំការចេកទី១ ឃុំក្រញូង និងភូមិព្រៃខ្លូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ដោយសារតែជនជាប់ចោទទាំងបួននាក់គឺជាប្រជាពលរដ្ឋ ជាមន្ត្រីនគរបាល និងមន្ត្រីសុរិយោដីដែលកំពុងរស់នៅ និងបម្រើការងារជាក់ស្តែងនៅទីតាំងដីជាកម្មវត្ថុនៃការលក់ទិញ ដើម្បីយកមកប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងបួននាក់ប៉ុណ្ណោះ។

១៧-ផ្អែកតាមចម្លើយរបស់ប្រជាពលរដ្ឋជាម្ចាស់ដីពិតប្រាកដមួយចំនួន ដែលបានឆ្លើយនៅចំពោះមន្ត្រីនគរបាលយុត្តិធម៌នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ដែលមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់សាក្សីជាមេភូមិ និងជាមេឃុំ ឯកសារលិខិតលក់ផ្តាច់ដែលចេញត្រឹមថ្នាក់ភូមិ-ឃុំជាច្រើនសន្លឹក ក៏ដូចជាចម្លើយរបស់ជនជាប់ចោទទាំងបួននាក់ ដែលអាចឱ្យតុលាការជឿបានថា ជនជាប់ចោទទាំងបួននាក់ពិតជាបានធ្វើសកម្មភាពក្នុងការប្រមូលទិញដីពីប្រជាពលរដ្ឋ ដើម្បីយកមកលក់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានមួយចំនួនពិតប្រាកដមែន ប៉ុន្តែទំហំនៃការប្រមូលនោះមិនទាន់គ្រប់ចំនួនទៅតាមទំហំមានចែងក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងកិច្ចព្រមព្រៀងបន្ថែម ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ហើយក៏មិនទាន់មានលក្ខណៈសមាមាត្រទៅនឹងទំហំទឹកប្រាក់ដែលជនជាប់ចោទទាំងបួននាក់បានទទួលពីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួននាក់នោះដែរ។

១៨-ជាមួយនឹងការប្រមូលទិញដីបានមួយចំនួនដូចមានបញ្ជាក់ក្នុងសំអាងហេតុចំណុចខាងលើ ជនជាប់ចោទក៏បានត្រឹមតែធ្វើជាកិច្ចសន្យាកក់ប្រាក់ឱ្យទៅប្រជាពលរដ្ឋម្ចាស់ដីពិតប្រាកដត្រឹមចំនួន ២០ដុល្លារអាមេរិក ហើយក្រោយមកមិនបានប្រគល់ប្រាក់គ្រប់ចំនួនតាមថ្លៃដីដែលដើមបណ្តឹងរដ្ឋប្បវេណីប្រគល់ឱ្យខ្លួន សម្រាប់យកទៅឱ្យប្រគល់ឱ្យទៅម្ចាស់ដីពិតប្រាកដនោះទេ ជាហេតុនាំឱ្យដាច់ប្រាក់កក់ មានការទាមទារយកដីត្រឡប់ទៅវិញ និងនាំឱ្យមិនទទួលបានដីពិតប្រាកដ ដើម្បីយកទៅប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីតាមកិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងកិច្ចព្រមព្រៀងបន្ថែម ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។ ចំណុចនេះគឺមានបញ្ជាក់យ៉ាងច្បាស់នៅក្នុងចម្លើយបំភ្លឺរបស់ប្រជាពលរដ្ឋម្ចាស់ដីពិតប្រាកដ ដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង និងចម្លើយបំភ្លឺនៅចំពោះមុខចៅក្រមស៊ើបសួររបស់សាក្សីជាមេភូមិ និងមេឃុំនៃទីតាំងដីជាកម្មវត្ថុនៃការលក់ទិញ។

១៩-ជាមួយគ្នានេះ មានឯកសារដែលត្រូវបានដាក់ឱ្យតុលាការពិនិត្យជារបាយការណ៍លេខ ៣០/២០ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ របស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកកំចាយមារ ខេត្តព្រៃវែង ចេញដោយលោកប្រធានការិយាល័យឈ្មោះ [redacted] សារទ់ ក៏ដូចជាឯកសារភ្ជាប់ជាបន្តបន្ទាប់ ដែលបានបង្ហាញពីការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីទាំងបួននាក់ឈ្មោះ [redacted] តុង ឈ្មោះ [redacted] ស្រ៊ីអ៊ុយ ឈ្មោះ [redacted] វ៉ាន់ឃួរ និងឈ្មោះ [redacted] អេង ថាមានដីទំហំ ៤៧៩.១២៦ម៉ែត្រការ៉េ នៅភូមិចំការចេកទី១ ឃុំក្រញូង និងទំហំ ៣៤៤.៨១៥ម៉ែត្រការ៉េ នៅភូមិព្រៃខ្លូលថ្មី ឃុំក្របៅ នៃស្រុកកំចាយមារ ខេត្តព្រៃវែង ប៉ុន្តែរបាយការណ៍នេះមិនអាចឱ្យជឿជាក់បានទេ ព្រោះវាត្រូវបានធ្វើឡើងដោយជនជាប់ចោទឈ្មោះ [redacted] សារទ់ ខ្លួនឯង ដែលប្រាកដណាស់ថាជនជាប់ចោទធ្វើឡើងដើម្បីជាការដោះបន្ទុកឱ្យខ្លួនអាចរួចផុតពីការចោទប្រកាន់ ហើយក៏មិនមានភស្តុតាងបញ្ជាក់ជាផ្លូវការណាមួយ អាចបង្ហាញថាដីទំហំ ៤៧៩.១២៦ម៉ែត្រការ៉េ នៅភូមិចំការចេកទី១ ឃុំក្រញូង និងទំហំ ៣៤៤.៨១៥ម៉ែត្រការ៉េ នៅភូមិព្រៃខ្លូលថ្មី ឃុំក្របៅ ត្រូវបានចុះបញ្ជីមកជាកម្មសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងបួននាក់នោះទេ។ ផ្ទុយទៅវិញ តាមការអះអាង

របស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់រួចហើយថា រហូតដល់ពេលនេះកូនក្តីខ្លួននៅមិនទាន់ទទួលបានកម្មសិទ្ធិដីពិតប្រាកដក្នុងទំហំណាមួយពីជនជាប់ចោទទាំងបួននាក់នោះដែរ។

២០-តាមពាក្យបណ្តឹង និងតាមការអះអាងរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី មានភាពស៊ីសង្វាក់គ្នានឹងចម្លើយរបស់សាក្សីជាមេភូមិ និងមេឃុំនៃទីតាំងដីជាកម្មវត្ថុនៃការលក់ទិញ ចម្លើយបំភ្លឺរបស់ប្រជាពលរដ្ឋជាម្ចាស់ដីពិតប្រាកដនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ព្រមទាំងស៊ីសង្វាក់ទៅនឹងភស្តុតាងដែលមាននៅក្នុងសំណុំរឿង ដែលភាពស៊ីសង្វាក់នេះ គឺជាអង្គហេតុ និងភស្តុតាងធ្វើឱ្យតុលាការជឿបានថា កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ពិតជាមានអង្គហេតុជនជាប់ចោទឈ្មោះ [redacted] វចនា ឈ្មោះ [redacted] សារ៉ន់ ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ បានចុះកិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ ជាមួយនឹងឈ្មោះ ណម តុង និងកិច្ចព្រមព្រៀងបន្ថែម ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted] វចនា ឈ្មោះ [redacted] សារ៉ន់ ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ ជាមួយនឹងឈ្មោះ [redacted] តុង ឈ្មោះ [redacted] ស្រីអ៊ុយ ឈ្មោះ [redacted] វ៉ាន់យូរ និងឈ្មោះ [redacted] អេង ពិតប្រាកដមែន ព្រមទាំងបានទទួលប្រាក់ចំនួន ២.០៣១.៣៨២ (ពីរលានសូន្យសែនបីម៉ឺនមួយពាន់បីរយប៉ែតសិបពីរ) ដុល្លារអាមេរិក ដែលជាប្រាក់សម្រាប់យកទៅទូទាត់ថ្លៃដីប្រាកដមែន ប៉ុន្តែជនជាប់ចោទទាំងបួននាក់មិនបានយកប្រាក់នោះទៅទូទាត់ឱ្យម្ចាស់ដីពិតប្រាកដ ឱ្យបានគ្រប់ចំនួនតាមដែលដើមបណ្តឹងរដ្ឋប្បវេណីបានប្រគល់ឱ្យនោះទេ ផ្ទុយទៅវិញជនជាប់ចោទបែរជាបានយកប្រាក់ទាំងនោះទៅប្រគល់ឱ្យម្ចាស់ដីត្រឹមមួយចំនួនប៉ុណ្ណោះ និងបានទុកប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួនមួយចំនួនទៀត ដូចទៅនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វចនា បានឆ្លើយសារភាពនៅចំពោះមុខចៅក្រមស៊ើបសួរថា [...] *ក្នុងលុយជាង២លានដុល្លារ ពួកខ្លួនទិញដីអស់ នៅសល់ប្រហែល៧០ម៉ឺនដុល្លារ គឺចំណាយទៅលើការត់ការកាត់ឈ្មោះ និងថ្លៃចាយវាយផ្សេងៗអស់ហើយ។* [...] ប៉ុន្តែការអះអាងថាបានចាយវាយផ្សេងៗ និងរត់ការរបស់ក្រុមជនជាប់ចោទនេះទៀតសោត ក៏ពុំមានភស្តុតាងអាចបញ្ជាក់ឱ្យតុលាការជឿបាននោះដែរ ផ្ទុយទៅវិញ ការបាត់បង់ប្រាក់ចំនួន៧០ម៉ឺនដុល្លារនេះ គឺជាការកែបំបាត់ដោយជនជាប់ចោទដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនប្រាកដមែន។

២១-តាមបញ្ញត្តិមាត្រា ៣៧៧ នៃក្រមព្រហ្មទណ្ឌ បានចែងថា *អំពើបន្លំចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬ ដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនោះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬ របស់តតិយជននូវ៖ ១-ការប្រគល់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ ២-ការផ្តត់ផ្គង់សេវា ៣-ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬ ជាការឱ្យរួចពីកាតព្វកិច្ច ជាបទ អំពើឆបោក។*

២២-តាមបញ្ញត្តិមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ បានចែងថា *អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។*

២៣-តាមបញ្ញត្តិមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ បានចែងថា *អំពើកែបំបាត់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ នាំឱ្យខូចខាតប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះយល់ព្រមដោយមានការកិច្ចប្រគល់សងវិញ បង្ហាញ ឬ យកមូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់ គឺជា អំពើរំលោភលើទំនុកចិត្ត។*

២៤-តាមមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ បានចែងថា *អំពើរំលោភលើទំនុក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ទៅ ៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។*



Scanned with CamScanner

២៥-តាមបញ្ញត្តិមាត្រា ៣៧៧ នៃក្រមព្រហ្មទណ្ឌនេះ អាចកំណត់បានថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សារទ់ ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ ពុំមានធាតុផ្សំជាបទល្មើស ឆបោក ដែលត្រូវផ្ដន្ទាទោសតាមមាត្រា ៣៧៨ នោះទេ ប៉ុន្តែមានធាតុផ្សំបទល្មើសជាបទ រំលោភលើទំនុកចិត្ត ដែលមានចែងតាមមាត្រា ៣៩១ និងត្រូវផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ គប្បីកែប្រែបទចោទប្រកាន់លើជនជាប់ចោទទាំងបួននាក់។

២៦-ផ្អែកតាមសំអាងហេតុខាងលើឃើញថា ការចោទប្រកាន់លើជនជាប់ចោទទាំងបួននាក់ថាបានប្រព្រឹត្តអំពើគៃបំបាត់យកប្រាក់សម្រាប់លក់ទិញដីពីប្រជាពលរដ្ឋម្ចាស់ដីពិតប្រាកដឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីទាំងបួននាក់ កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ ពុំទាន់មានលក្ខណៈត្រឹមត្រូវទេ គប្បីកែប្រែកាលបរិច្ឆេទនៃការប្រព្រឹត្តទៅជា កាលពីអំឡុងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ដែលជាកាលបរិច្ឆេទនៃការបង្កើតកិច្ចព្រមព្រៀងទាំងពីរលើក និងជាការចាប់ផ្ដើមនៃអំពើគៃបំបាត់ប្រាក់សម្រាប់ទិញដីជាបន្តបន្ទាប់របស់ជនជាប់ចោទទាំងបួននាក់។

២៧-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សារទ់ ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ ពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃខ្វលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីអំឡុងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២៨-នាពេលប្រព្រឹត្តបទល្មើសជនជាប់ចោទឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សារទ់ ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ គឺជានីតិជន និងជាជនមានសមត្ថភាពពេញលេញក្នុងការយល់ដឹងពីអំពើរបស់ខ្លួន និងលទ្ធផលតាមផ្លូវច្បាប់ ដូច្នេះជនជាប់ចោទអាចទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួនតាមផ្លូវច្បាប់បាន។

២៩-អំពើដែលជនជាប់ចោទឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សារទ់ ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់ របៀបរៀបរយសង្គម និងប៉ះពាល់ដល់ទ្រព្យសម្បត្តិជាប្រាក់របស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងបួននាក់ក្នុងទំហំដ៏ច្រើន។

៣០-ជនជាប់ចោទឈ្មោះ [redacted] រចនា និងឈ្មោះ គួន សុវណ្ណ គឺជាជនសកម្មក្នុងការផ្ដើមគំនិតរៀបចំដី ការប្រមូលទិញដីពីប្រជាពលរដ្ឋ ការទទួលយកប្រាក់ ការកាន់កាប់ប្រាក់ និងគ្រប់គ្រងប្រាក់សម្រាប់ទូទាត់ឱ្យទៅប្រជាពលរដ្ឋដែលជាម្ចាស់ដីពិតប្រាកដ ប៉ុន្តែបានយកទុកធ្វើជាប្រយោជន៍របស់ខ្លួនដូចមានក្នុងកំណត់ហេតុចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] រចនា បានបញ្ជាក់ខាងលើ និងដែលត្រូវបានឯកភាពដោយជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ នៅក្នុងកំណត់ហេតុសួរចម្លើយចំពោះមុខចៅក្រមស៊ើបសួររបស់ជនជាប់ចោទរូបនេះ។ ជាងនេះទៅទៀតជនជាប់ចោទឈ្មោះ [redacted] រចនាក៏បានអះអាងពីការទទួលខុសត្រូវតែម្នាក់ឯង ដោយមិនមានពាក់ព័ន្ធនឹងជនជាប់ចោទដទៃផងដែរ។ គប្បីលើកយកចំណុចទាំងនេះមកពិចារណាក្នុងការសម្រេចអំពីទោសលើជនជាប់ចោទទាំងពីរនាក់នេះក្នុងលក្ខណៈធ្ងន់ជាងជនជាប់ចោទដទៃ។

៣១-ជនជាប់ចោទឈ្មោះ [redacted] សារទ់ និងឈ្មោះ [redacted] សុខុម គឺជាមន្ត្រីរាជការ និងជាមន្ត្រីនគរបាល ដែលធ្លាប់បានបម្រើការងារដល់ប្រជាពលរដ្ឋ អាចធ្លាប់មានគុណសម្បត្តិខ្លះ ទើបតែប្រព្រឹត្តបទល្មើសមជ្ឈិមជាលើកទី១ និងមិនដែលធ្លាប់ត្រូវបានផ្ដន្ទាទោសពីមុនមក ណាមួយក៏មិនមែនជាសកម្មជនដែលបានកាន់កាប់ប្រាក់ និងគ្រប់គ្រងប្រាក់ដែលបានទទួលពីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការស្វែងរកទិញដី និងប្រគល់ឱ្យប្រជាពលរដ្ឋម្ចាស់ដីពិតប្រាកដដោយផ្ទាល់នោះដែរ។ តាមហេតុផលទាំងនេះឃើញថា លក្ខខណ្ឌនៃការព្យួរទោសមានចែងតាមមាត្រា ១០៦ និងមាត្រា ១០៧ ត្រូវបានបំពេញ។ គប្បីពិចារណាផ្ដល់នូវការព្យួរទោសដល់ជនជាប់ចោទទាំងពីរនាក់។



Scanned with CamScanner

៣២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីអ៊ុយ ឈ្មោះ [redacted]តុង ឈ្មោះ [redacted] វ៉ាន់យូ ឈ្មោះ [redacted]អេង បាន ប្តឹងទាមទារសំណងចំនួន ២.០៣១.៣៨២ (ពីរលានបីម៉ឺនមួយពាន់បីរយប៉ែតសិបពីរ) ដុល្លារអាមេរិក និងសំណងជំងឺចិត្ត និងការខូចខាតបង់ផ្សេងៗចំនួន ៥០០.០០០ (ហាសិបម៉ឺន) ដុល្លាររអាមេរិក។ ការទាមទារសំណងរបស់ដើមបណ្តឹងមាន លក្ខណៈស្របតាមមាត្រា ១៣ មាត្រា ១៤ និងមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ គប្បីពិចារណាផ្តល់នូវសំណងធួន ល្មមទៅនឹងការខូចខាតជាក់ស្តែងរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង និងដែលត្រូវបានទទួលស្គាល់រួចហើយដោយ ជនជាប់ចោទ។ ដោយឡែកជម្ងឺចិត្តដែលដើមបណ្តឹងបានទាមទារ គប្បីលើកយកមកពិចារណាដោយផ្តល់ឱ្យស្របតាម បញ្ញត្តិស្តីពីការប្រាក់តាមច្បាប់ត្រឹមទំហំ ០៥ (ប្រាំ) ភាគរយក្នុងមួយឆ្នាំមានចែងក្នុងក្រមរដ្ឋប្បវេណី និងគិតពីពេលចាប់ ផ្តើមប្រព្រឹត្តរហូតមកដល់ពេលបច្ចុប្បន្ន និងដោយពិចារណាដល់លទ្ធភាពនៃការសងរបស់ជនជាប់ចោទផងដែរ។

៣៣-មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋាន សុំឱ្យតុលាការសម្រេចតាមផ្តន្ទាទោសជន ជាប់ចោទតាមច្បាប់ឱ្យបានធ្ងន់ធ្ងរ និងស្នើសុំចេញដីកាបង្គាប់ឱ្យចាប់ខ្លួនតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ការស្នើសុំនេះគប្បីតុលាការលើកយកមកពិចារណា និងសម្រេចស្របតាមសំអាងហេតុខាងលើ។

៣៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា សុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរទុកជាបាន ការដដែល។ សេចក្តីសន្និដ្ឋាននេះមិនទាន់មានលក្ខណៈត្រឹមត្រូវលើបទចោទប្រកាន់នោះទេ គប្បីតុលាការពិចារណាកែប្រែ បទចោទប្រកាន់ស្របតាមសំអាងហេតុខាងលើ និងយកមកពិចារណាលើការស្នើសុំពាក់ព័ន្ធនឹងការសម្រេចអំពីទោស។

breach of trust

៣៥-សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងបួននាក់ដែលមានក្នុងសំណុំរឿង គប្បី លើកយកមកពិចារណា និងសម្រេចស្របតាមសំអាងហេតុខាងលើ។

## ហេតុដូច្នេះសម្រេច

១-កែប្រែបទចោទលើជនជាប់ចោទឈ្មោះ [redacted] រចនា ភេទប្រុស អាយុ ៣៩ឆ្នាំ ឈ្មោះ [redacted]សារន់ ភេទប្រុស អាយុ ៥១ឆ្នាំ ឈ្មោះ [redacted]សុខុម ភេទប្រុស អាយុ ៥៤ឆ្នាំ និងឈ្មោះ[redacted] សុវណ្ណ ភេទប្រុស អាយុ ២៩ឆ្នាំ (អត្តសញ្ញាណ ខាងលើ) ពីបទ ឆបោក ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃខ្លូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្ត ព្រៃវែង កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ទៅជាបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃខ្លូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីអំឡុងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃ ក្រមព្រហ្មទណ្ឌ។

២-ផ្តន្ទាទោសជនជាប់ចោទ៖

២.១-ឈ្មោះ [redacted]រចនា ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ

២.២-ឈ្មោះ[redacted]សុវណ្ណ ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០១ (មួយ) ឆ្នាំ ពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចភូមិ ចំការចេក១ ឃុំក្រញូង និងភូមិព្រៃខ្លូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីអំឡុងថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០១៧ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២.៣-ឈ្មោះ[redacted] សារន់ ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ



Scanned with CamScanner

២.៤-ឈ្មោះ [redacted] សុខុម ភេទប្រុស អាយុ ៥៤ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០១ (មួយ) ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា ពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃខ្វលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីអំឡុងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ មាត្រា ៣៩២ មាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

៣-បង្គាប់ឱ្យឈ្មោះ [redacted] វចនា ភេទប្រុស អាយុ ៣៩ឆ្នាំ ឈ្មោះ [redacted] សារទ់ ភេទប្រុស អាយុ ៥១ឆ្នាំ ឈ្មោះ [redacted] សុខុម ភេទប្រុស អាយុ ៥៤ឆ្នាំ និងឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ ២៩ឆ្នាំ រួមគ្នាសងសំណងដូចខាងក្រោម៖

៣.១-ការខូចខាតជាប្រាក់ចំនួន ២.០៣១.៣៨២ (ពីរលានសូន្យសែនបីម៉ឺនមួយពាន់បីរយប៉ែតសិបពីរ) ដុល្លារអាមេរិក

៣.១-ជំងឺចិត្តជាប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល

ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រ៊ីអ៊ិយ ឈ្មោះ [redacted] តុង ឈ្មោះ [redacted] វ៉ាន់យូ និងឈ្មោះ [redacted] អេង តាមបញ្ញត្តិមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ច្រានចោលការទាមទារលើសពីនេះ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] វចនា ឈ្មោះ [redacted] សារទ់ ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រ៊ីអ៊ិយ ឈ្មោះ [redacted] តុង ឈ្មោះ [redacted] វ៉ាន់យូ ឈ្មោះ [redacted] អេង និងប្រកាសជាសាធារណៈ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២។

ភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ៦កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner